# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦១ សសរ

# សេចក្តីសម្រេច

ស្តីពី

ការបង្កើតយន្តការប្រតិកម្មរហ័ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១:** ត្រូវបានបង្កើតយន្តការសម្រាប់ធ្វើប្រតិកម្មរហ័ស ចំពោះមតិអវិជ្ជមានរបស់មជ្ឈដ្ឋាននានាមកលើរាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ជុំ ប៊ុនរ៉ុង | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម ផៃ ស៊ីផាន | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | អនុប្រធាន |
| ៣-ឯកឧត្តម ម៉ល់ រឿង | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៤-ឯកឧត្តម យូ ស៊ុនឡុង | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ៦-ឯកឧត្តម ជុម ហាក់ | មេបញ្ជាការរងកងទ័ពជើងគោក | សមាជិក |
| ៧-ឯកឧត្តម សុខ ផល | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៨-ឯកឧត្តម ប៉ាឈំ ចន្ទតារា | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ៩-ឯកឧត្តម ជីវ សុខហាក់ | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០-ឯកឧត្តម ស៊ាន មូរ៉ាត | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ១១-ឯកឧត្តម ម៉ៅ អាយុទ្ធ | ប្រធានសមាគមទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ១២-ឯកឧត្តម អ៊ិន ទីរៈជាតិ | ប្រធានសមាគមគ្រឹះស្ថានឧត្តមសិក្សា | សមាជិក |
| ១៣-ឯកឧត្តម មួន លីមហេង | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច | សមាជិក |
| ១៤-លោក ជា សំអាង | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១៥-លោក ឡុង ឈាង | អនុប្រធានរដ្ឋបាលជលផល | សមាជិក |
| ១៦-លោក សួន ស៊ីផាត | ប្រធានលេខាធិការដ្ឋានគណៈកម្មការ សុរិយោដីជាតិ | សមាជិក |
| ១៧-លោកស្រី អ៊ុក សីហា | អនុប្រធាននាយកដ្ឋានអភិរក្សធនធានធម្មជាតិ ក្រសួងបរិស្ថាន | សមាជិក |
| ១៨-លោក សោម អូន | ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារសហជីព | សមាជិក |
| ១៩-លោក ទៅ ទាសនា | ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារអង្គការមិនមែនរដ្ឋាភិបាល | សមាជិក |
| ២០-លោក សេង សាធន | ប្រធាននាយកដ្ឋានព័ត៌មាន | សមាជិក |
| ២១-នាយក នាយិកាខុទ្ទកាល័យគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន | | សមាជិក |

ប្រការ ២: យន្តការនេះមានភារកិច្ច ដូចតទៅ :

-សិក្សា និងទប់ស្កាត់មតិរិះគន់មានទាំងឡាយដែលអាចកើតឡើងចំពោះរាជរដ្ឋាភិបាល ដោយធ្វើការផ្សព្វផ្សាយព័ត៌មានពិតជាមុន ជូនសាធារណមតិជាតិ និងអន្តរជាតិ

-ផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងបញ្ហារសើប

-រៀបចំឯកសារបកស្រាយពន្យល់ និងឆ្លើយបំភ្លឺចំពោះមតិរិះគន់មានដែលមជ្ឈដ្ឋានក្នុង និងក្រៅប្រទេសបានចេញផ្សាយ

-សិក្សាតាមផ្លូវច្បាប់ ចំពោះការផ្សព្វផ្សាយព័ត៌មានមិនពិត

-រាយការណ៍ពីលទ្ធផលសិក្សា លើកវិធានការ និងសុំការសម្រេចពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

មុនចាត់វិធានការដូចរៀបរាប់ខាងលើ។

**ប្រការ ៣:** យន្តការនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅទីស្តីការគណៈរដ្ឋមន្ត្រី។ លេខាធិការដ្ឋាននេះ ដឹកនាំដោយ ឯកឧត្តម ស៊ុខ សាឆ ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៤:** សមាជិកនៃយន្តការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

យន្តការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយចំណាយក្នុងដំណើរការការងារជាបន្ទុកថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com